# អំណាចបព្វជិតភាព

ប្រធាន ថូម៉ាស អេស ម៉នសុន

*សូមឲ្យយើងក្លាយជាអ្នកទទួលខុសត្រូវចំពោះអំណាចបព្វជិតភាពដ៏ទេវភាពដែលយើងកាន់ ។ សូមឲ្យអំណាចនោះប្រទានដល់យើង ហើយសូមឲ្យយើងប្រើវាដើម្បីប្រទានពរដល់ជីវិតអ្នកដទៃ ។*

ខ្ញុំបានអធិស្ឋានហើយបានសិក្សាយ៉ាងយូរអំពីអ្វីដែលខ្ញុំចង់លើកឡើងនាពេលរាត្រីនេះ ។ ខ្ញុំមិនចង់ធ្វើឲ្យនរណាម្នាក់អាក់អន់ចិត្តនោះឡើយ ។ ខ្ញុំបានគិតថា « តើយើងមានឧបសគ្គអ្វីខ្លះ ? តើមានរឿងអ្វីខ្លះដែលខ្ញុំប្រឈមមុខជារៀងរាល់ថ្ងៃ ដែលធ្វើឲ្យខ្ញុំសោកសៅរហូតដល់យប់អាធ្រាត្រ ? » ខ្ញុំបានគិតថា ខ្ញុំនឹងព្យាយាមដើម្បីលើកឡើងពីឧបសគ្គទាំងនោះមួយចំនួននាពេលរាត្រីនេះ ។ រឿងមួយចំនួននឹងអនុវត្តចំពោះពួកយុវជន ។ រឿងមួយចំនួនអនុវត្តចំពោះមនុស្សវ័យកណ្ដាល ។ ខ្លះនឹងអនុវត្តចំពោះមនុស្សដែលមានអាយុលើសវ័យកណ្ដាលបន្តិច ។ យើងនឹងមិនលើកឡើងពីមនុស្សវ័យចំណាស់ឡើយ ។

ហេតុដូច្នេះហើយ ខ្ញុំចង់ចាប់ផ្ដើមដោយនិយាយយ៉ាងសាមញ្ញថា ជាការល្អណាស់ដែលយើងបានជួបជុំគ្នានៅល្ងាចនេះ ។ យើងបានឮនូវសារលិខិតដ៏អស្ចារ្យទាំងឡាយ និងត្រូវនឹងសម័យកាល ដែលទាក់ទងនឹងបព្វជិតភាពនៃព្រះ ។ ខ្ញុំ ជាមួយអ្នក ត្រូវបានលើកឡើង និងបំផុសគំនិត ។

រាត្រីនេះ ខ្ញុំចង់លើកឡើងពីបញ្ហាទាំងឡាយដែលដក់ក្នុងគំនិតខ្ញុំយ៉ាងខ្លាំងនាពេលថ្មីៗនេះ ហើយដែលខ្ញុំមានចំណាប់អារម្មណ៍ចង់ចែកចាយជាមួយអ្នក ។ ទោះតាមរបៀបណាក៏ដោយ បញ្ហាទាំងអស់នោះគឺទាក់ទងទៅនឹងភាពស័ក្តិសមផ្ទាល់ខ្លួន ដែលតម្រូវឲ្យទទួល និងអនុវត្តអំណាចដ៏ពិសិដ្ឋនៃបព្វជិតភាពដែលយើងកាន់ ។

សូមឲ្យខ្ញុំចាប់ផ្ដើម ដោយការអានដល់អ្នកពីកណ្ឌទី 121 ក្នុងគោលលទ្ធិ និងសេចក្ដីសញ្ញាថា ៖ « សិទ្ធិទាំងឡាយនៃបព្វជិតភាព គឺជាប់ជាមួយនឹងអំណាចទាំងឡាយនៃស្ថានសួគ៌ ដែលមិនអាចបំបែកបានឡើយ ហើយថាអំណាចនៃស្ថានសួគ៌ពុំអាចត្រួតត្រា ឬកាន់កាប់បានឡើយ លើកលែងតែដោយគោលការណ៍នៃសេចក្ដីសុចរិតប៉ុណ្ណោះ ។ ឯកសិទ្ធិទាំងឡាយអាចបានប្រទានមកលើយើង នោះពិតមែនហើយ ប៉ុន្តែនៅពេលយើងខំស្វែងរកផ្លូវ ដើម្បីលាក់អំពើបាបទាំងឡាយរបស់យើង ឬដើម្បីបំពេញសេចក្ដីឆ្មើងឆ្មៃរបស់យើង សេចក្ដីប៉ងប្រាថ្នាដ៏ឥតប្រយោជន៍របស់យើង ឬដើម្បីអនុវត្តការត្រួតត្រា ឬការគ្រប់គ្រង ឬការបង្ខិតបង្ខំទៅលើព្រលឹងនៃកូនចៅមនុស្ស ដោយនូវសេចក្ដីឥតសុចរិតណាមួយ មើលចុះ ស្ថានសួគ៌ដកខ្លួនចេញ ព្រះវិញ្ញាណព្រះអម្ចាស់ថប់អារម្មណ៍ ហើយកាលណាព្រះវិញ្ញាណថយចេញ បព្វជិតភាព ឬសិទ្ធិអំណាចនៃមនុស្ស នោះត្រូវបានបញ្ចប់ » ។[1]

បងប្អូនប្រុស នោះគឺជាព្រះបន្ទូលដ៏មានអំណាចរបស់ព្រះអម្ចាស់ ដែលទាក់ទងទៅនឹងសិទ្ធិអំណាចដ៏ទេវភាពរបស់ទ្រង់ ។ យើងមិនអាចឋិតនៅក្នុងភាពសង្ស័យចំពោះកាតព្វកិច្ចដែលបទគម្ពីរនេះបានដាក់មកលើយើងម្នាក់ៗ ដែលអ្នកកាន់បព្វជិតភាពនៃព្រះនោះទេ ។

យើងបានមកផែនដីក្នុងគ្រាដ៏វឹកវរ ។ បទដ្ឋានសីលធម៌នៃមនុស្សទូទៅ បានផ្លាស់ប្ដូរបន្តិចម្ដងៗ ទៅជាឥរិយាបថមួយដែលថា « ធ្វើអ្វីក៏បាន » ។

ខ្ញុំបានរស់នៅយូរគ្រប់គ្រាន់នឹងអាចធ្វើជាសាក្សីជាច្រើន ចំពោះការប្រែប្រួលនៃសីលធម៌សង្គម ។ មានពេលមួយ ដែលបទដ្ឋានសាសនាចក្រ និងបទដ្ឋានសង្គមស្ទើរតែអាចត្រដមត្រសងគ្នាបាន តែឥឡូវនេះ មាននូវការខ្វែងគំនិតយ៉ាងធំជាមួយយើង ហើយវារីកកាន់តែធំឡើងៗ ។

ភាពយន្ត និងកម្មវិធីទូរទស្សន៍ជាច្រើន បង្ហាញពីការប្រព្រឹត្តិដែលផ្ទុយស្រឡះពីច្បាប់របស់ព្រះតែម្ដង ។ សូមកុំដាក់ខ្លួនអ្នកឲ្យនៅក្រោមការនិយាយពាក្យដៀមដាម និងអ្វីដែលកខ្វក់ពេញទី ដែលជាញឹកញាប់មាននៅក្នុងភាពយន្ត និងកម្មវិធីទូរទស្សន៍ទាំងនោះ ។ ទំនុកច្រៀងនៅក្នុងបទចម្រៀងសព្វថ្ងៃនេះ ត្រូវបានដាក់នៅក្នុងប្រភេទដូចគ្នា ។ ជាទូទៅ ភាពមិនពិសិដ្ឋដែលនៅជុំវិញយើងសព្វថ្ងៃនេះនឹងមិនរលាយបាត់ដោយងាយៗនោះឡើយ ។ ព្រះនាមរបស់ព្រះអម្ចាស់ត្រូវបានប្រើជាអសារឥតការ ម្ដងហើយម្ដងទៀត ។ សូមរំឭកឡើងវិញជាមួយខ្ញុំនូវបទបញ្ញត្តិមួយ ---ក្នុងក្រឹត្យវិន័យដប់ប្រការ ---ដែលព្រះអម្ចាស់បានបើកសម្ដែងដល់ ម៉ូសេ លើភ្នំស៊ីណាយ ថា ៖ « កុំឲ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា ជាព្រះនៃឯងជាអសារឥតការឡើយ ត្បិតព្រះយេហូវ៉ាទ្រង់មិនរាប់ជាឥតទោសដល់អ្នកណា ដែលចេញព្រះនាមទ្រង់ជាអសារឥតការនោះទេ » ។[2] ខ្ញុំសោកស្ដាយដែលមានពួកយើងមួយចំនួនបានជ្រើសរើសប្រើភាសាអសុរោះ ហើយខ្ញុំសូមអង្វរដល់អ្នក សូមកុំប្រើវា ។ ខ្ញុំសូមអង្វរដល់អ្នក សូមកុំនិយាយ ឬធ្វើអ្វីដែលធ្វើឲ្យអ្នកបាត់បង់នូវមោទនភាពឡើយ ។

សូមនៅឲ្យឆ្ងាយទាំងស្រុងពីរូបអាសគ្រាម ។ កុំអនុញ្ញាតខ្លួនឯងឲ្យមើលវាសោះឡើយ ។ វាត្រូវបានសឲ្យឃើញថាជាការញៀន ដែលពិបាកនឹងយកឈ្នះខ្លាំងណាស់ ។ ជៀសវាងពីគ្រឿងស្រវឹង និងថ្នាំជក់ ឬថ្នាំផ្សេងៗដែលញៀនផងដែរ ដែលអ្នកនឹងឃើញថាពិបាកនឹងយកឈ្នះ ។

តើអ្វីដែលនឹងការពារអ្នកពីអំពើបាប និងអំពើអាក្រក់ដែលនៅជុំវិញអ្នក ? ខ្ញុំសូមប្រកាន់ខ្ជាប់ថា ទីបន្ទាល់ដ៏រឹងមាំពីព្រះអង្គសង្គ្រោះរបស់អ្នក និងដំណឹងល្អរបស់ទ្រង់ នឹងនាំអ្នកទៅកាន់ទីសុវត្ថិភាព ។ បើអ្នកមិនបានអានព្រះគម្ពីរមរមនទេ សូមអានវា ។ បើអ្នកអានវា ដោយការអធិស្ឋាន និងដោយចេតនាពិត នោះព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញសេចក្ដីពិតរបស់វាដល់អ្នក ។ ហើយបើវាជាព្រះគម្ពីរពិត ---ហើយវា*ពិតមែន*---នោះយ៉ូសែប ស្ម៊ីធ គឺជាព្យាការី ដែលបានឃើញព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។ សាសនាចក្រនេះពិត ។ បើអ្នកមិនទាន់មានទីបន្ទាល់ពីការណ៍ទាំងអស់នេះទេ អ្នកត្រូវធ្វើការណ៍ដែលចាំបាច់ដើម្បីទទួលទីបន្ទាល់នោះ ។ វាចាំបាច់ណាស់សម្រាប់អ្នក ដើម្បីមានទីបន្ទាល់ផ្ទាល់ខ្លួន ត្បិតទីបន្ទាល់របស់អ្នកដទៃទៀតគ្រាន់តែជួយអ្នកក្នុងកម្រិតមួយប៉ុណ្ណោះ ។ ពេលបានទទួលហើយ ទីបន្ទាល់នោះត្រូវការរក្សាឲ្យដូចជាជីវិត ហើយត្រូវឲ្យមានភាពរស់រវើក តាមរយៈការគោរពដល់បទបញ្ញត្តិទាំងឡាយនៃព្រះ និងតាមរយៈការអធិស្ឋាន និងសិក្សាព្រះគម្ពីរជាទៀងទាត់ ។ ទៅព្រះវិហារ ។ យុវជន អ្នកគួរតែចូលរៀននៅថ្នាក់សិក្ខាសាលា និងវិទ្យាស្ថាន បើថ្នាក់ទាំងនោះមាននៅកន្លែងអ្នក ។

បើមានអ្វីដែលមិនល្អក្នុងជីវិតរបស់អ្នក នោះអ្នកមានផ្លូវចេញ ។ ឈប់ធ្វើអ្វីដែលមិនសុចរិត ។ និយាយជាមួយប៊ីស្សពរបស់អ្នក ។ បញ្ហាអ្វីក៏ដោយ ក៏អាចដោះស្រាយបានដែរ តាមរយៈការប្រែចិត្តដ៏ត្រឹមត្រូវ ។ អ្នកអាចបានស្អាតម្តងទៀត ។ ព្រះអម្ចាស់មានបន្ទូល ពីពួកអ្នកប្រែចិត្តថា « ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទង់ដែងក៏ដោយ គង់តែនឹងបានសដូចហិមៈ »[3] « ហើយយើងជាព្រះអម្ចាស់មិនចាំពីអំពើបាបទាំងនោះទៀតទេ » ។[4]

ព្រះអង្គសង្គ្រោះនៃមនុស្សលោកបានពណ៌នាពីអង្គទ្រង់ថា នៅក្នុងលោកិយ តែមិនមែនជារបស់លោកិយទេ ។[5] ដូចគ្នានេះយើងក៏អាចនៅក្នុងលោកិយ ប៉ុន្តែមិនមែនជារបស់លោកិយទេ កាលណាយើងបដិសេធគំនិតខុសឆ្គង និងការបង្រៀនក្លែងក្លាយ និងបន្តពិតចំពោះអ្វីដែលព្រះបានដាក់បញ្ញត្ត ។

ឥឡូវ ខ្ញុំបានបង្រៀនជាច្រើនពីអ្នកជាបុរសវ័យក្មេង ដែលស្ថិតក្នុងអាយុរៀបការ តែមិនទាន់ចង់ធ្វើដូច្នោះ ។ ខ្ញុំបានឃើញស្ត្រីវ័យក្មេងដ៏គួរឲ្យស្រឡាញ់ជាច្រើន ដែលមានបំណងចង់រៀបការ និងចិញ្ចឹមបីបាច់ក្រុមគ្រួសារ ប៉ុន្តែឱកាសរបស់ពួកគេត្រូវបានកំណត់ ដោយសារតែបុរសវ័យក្មេងជាច្រើនកំពុងពន្យារពេលក្នុងការរៀបការ ។

នេះមិនមែនជាស្ថានភាពថ្មីនោះទេ ។ រឿងនេះត្រូវបាននិយាយជាច្រើន ដោយប្រធានចាស់ៗនៃសាសនាចក្រ ។ ខ្ញុំសូមចែកចាយជាមួយអ្នក តែគំរូមួយ ឬពីរប៉ុណ្ណោះ ពីដំបូន្មានរបស់ពួកគាត់ ។

ប្រធាន ហារ៉ូល ប៊ី លី បានមានប្រសាសន៍ថា « យើងមិនបានកំពុងបំពេញករណីយកិច្ចរបស់យើង ជាអ្នកកាន់បព្វជិតភាពនោះទេ នៅពេលដែលយើងទៅហួសពីអាយុដែលអាចរៀបការបាន ហើយដកខ្លួនឯងចេញពីអាពាហ៍ពិពាហ៍ដ៏ខ្ពង់ខ្ពស់ជាមួយនឹងស្ត្រីដ៏គួរឲ្យស្រឡាញ់ទាំងនេះ » ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍ថា ៖ « ដួងចិត្តរបស់ខ្ញុំឈោងទៅឯ… ប្អូនស្រីដែលនៅលីវទាំងឡាយរបស់យើង ដែលចង់បានអាពាហ៍ពិពាហ៍មួយយ៉ាងខ្លាំង ហើយហាក់បីដូចជាមិនអាចរកវាបាន ។ …ខ្ញុំមានការអាណិតអាសូរតិចជាងឆ្ងាយណាស់ ចំពោះបុរសវ័យក្មេងទាំងឡាយដែលនៅក្នុងទំនៀមទម្លាប់នៃសង្គមរបស់យើង គេមានបុព្វសិទ្ធិ ដើម្បីចាប់ផ្តើមរឿងទាំងនេះមុន ប៉ុន្តែបុរសវ័យក្មេងជាច្រើនមិនបានធ្វើដូច្នោះទេ » ។

ខ្ញុំដឹងថា មានមូលហេតុជាច្រើន ដែលអាចធ្វើឲ្យអ្នកមានការរុញរា ដើម្បីបោះជំហានចូលក្នុងអាពាហ៍ពិពាហ៍ ។ បើអ្នកមានកង្វល់ពីការផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុសម្រាប់ភរិយា និងគ្រួសារ នោះខ្ញុំសូមអះអាងចំពោះអ្នកថា គ្មានការខ្មាសអៀនអ្វីទេ ដែលប្ដីប្រពន្ធមួយគូត្រូវតែចាយវាយតិចតួច ហើយសន្សំសំចៃនោះ ។ ជាទូទៅ គឺអំឡុងពេលនៃការលំបាកទាំងនេះហើយ ដែលអ្នកនឹងលូតលាស់ជាមួយគ្នា កាលដែលអ្នករៀនដើម្បីលះបង់ និងរៀនធ្វើការសម្រេចចិត្តដែលពិបាកៗ ។ ប្រហែលជាអ្នកខ្លាចថានឹងធ្វើការជ្រើសរើសខុស ។ ចំពោះរឿងនេះ ខ្ញុំសូមនិយាយថា អ្នកត្រូវអនុវត្តសេចក្ដីជំនឿ ។ សូមស្វែងរកនរណាម្នាក់ដែលអ្នកអាចស្រុះស្រួលជាមួយបាន ។ ត្រូវដឹងថា អ្នកនឹងមិនអាចមើលឃើញជាមុននូវគ្រប់ឧបសគ្គដែលនឹងកើតនោះទេ ប៉ុន្តែ ត្រូវប្រាកដថា ស្ទើរតែគ្រប់អ្វីៗទាំងអស់អាចដោះស្រាយបាន បើអ្នកប្រសព្វកៃខែ ហើយបើសិនអ្នកមានការតាំងចិត្តដើម្បីធ្វើឲ្យជីវិតអាពាហ៍ពិពាហ៍របស់អ្នកបានជោគជ័យ ។

ប្រហែលជាអ្នកមានការសប្បាយច្រើនបន្តិចក្នុងភាពនៅលីវ មានវិស្សមកាលដ៏ហ៊ឺហា ទិញឡាន និងរបស់របរថ្លៃៗ ហើយគ្រាន់តែសប្បាយជាមួយនឹងជីវិតជាមួយនឹងមិត្តភក្តិ ដោយមិនបាច់ខ្វល់ខ្វាយពីអ្វី ។ ខ្ញុំបានជួបជាមួយនឹងក្រុមមនុស្សដូចនោះ ហើយខ្ញុំឆ្ងល់ថាហេតុអ្វីបានជាអ្នកមិនចេញទៅក្រៅជាមួយនឹងស្ត្រីវ័យក្មេងដ៏ល្អទាំងឡាយ ។

បងប្អូនប្រុស មានចំណុចមួយ ដែលវាដល់ពេលហើយ ដើម្បីគិតឲ្យបានហ្មត់ចត់ពីការរៀបការ និងដើម្បីស្វែងរកដៃគូមួយដែលអ្នកចង់ចំណាយពេលជាមួយអស់កល្បជានិច្ច ។ បើអ្នកជ្រើសរើសដោយឈ្លាសវៃ ហើយបើអ្នកតាំងចិត្តដើម្បីធ្វើឲ្យអាពាហ៍ពិពាហ៍របស់អ្នកបានជោគជ័យ នោះគ្មានអ្វីក្នុងជីវិតនេះដែលនឹងនាំសុភមង្គលជាងនេះនោះទេ ។

ពេលអ្នករៀបការ អ្នកនឹងប្រាថ្នាដើម្បីរៀបការក្នុងដំណាក់នៃព្រះអម្ចាស់ ។ ត្បិតអ្នកដែលជាអ្នកកាន់បព្វជិតភាព មិនគួរមានជម្រើសណាផ្សេងក្រៅពីនេះនោះទេ ។ សូមប្រុងប្រយ័ត្ន ចំពោះលក្ខណៈស័ក្តិសមរបស់អ្នកក្នុងការរៀបការ ដើម្បីកុំឲ្យត្រូវបំផ្លាញ ។ អ្នកអាចរក្សាការចៃចង់អ្នកក្នុងព្រំដែនសមរម្យ ប៉ុន្តែនៅតែអាចមានពេលវេលាដ៏អស្ចារ្យមួយ ។

ឥឡូវនេះ បងប្អូនប្រុស ខ្ញុំបង្វែរទៅប្រធានបទមួយទៀត ដែលខ្ញុំមានចំណាប់អារម្មណ៍ថាត្រូវនិយាយទៅកាន់អ្នក ។ ក្នុងរយៈពេលបីឆ្នាំហើយ តាំងពីខ្ញុំត្រូវបានគាំទ្រជាប្រធាននៃសាសនាចក្រ ខ្ញុំជឿថា ការទទួលខុសត្រូវដ៏សោកសៅបំផុត និងបាក់ទឹកចិត្តបំផុត នោះគឺខ្ញុំត្រូវតែដោះស្រាយជាមួយនឹងការលប់ចោលនូវការផ្សារភ្ជាប់ ។ ម្នាក់ៗត្រូវបានប្រាប់ឲ្យដឹងជាមុនពីការរៀបការដ៏រីករាយមួយក្នុងដំណាក់នៃព្រះអម្ចាស់ ជាកន្លែងដែលប្ដីប្រពន្ធជាទីស្រឡាញ់ចាប់ផ្ដើមជីវិតថ្មីមួយជាមួយគ្នា ហើយរង់ចាំដើម្បីចំណាយពេលនៃជីវិតដ៏នៅអស់កល្បជានិច្ចជាមួយគ្នា ។ ហើយបន្ទាប់ពី ប៉ុន្មានខែឆ្នាំកន្លងទៅ ដោយសារមូលហេតុនេះ ឬមូលហេតុនោះ នោះក្ដីស្រឡាញ់ក៏ស្លាប់ទៅ ។

វាអាចជាលទ្ធផលនៃបញ្ហាហិរញ្ញវត្ថុ ការខ្វះការទំនាក់ទំនង ការមិនចេះទប់ចិត្ត ការជ្រៀតជ្រែកពីខាងសាច់ថ្លៃ ការជាប់ជំពាក់ក្នុងអំពើបាប ។ មានមូលហេតុជាច្រើនណាស់ ។ នៅក្នុងករណីច្រើនបំផុត លទ្ធផលមិនចាំបាច់តែជាការលែងលះនោះទេ ។

សំណើសុំសម្រាប់ការលប់ចោលការផ្សារភ្ជាប់ភាគច្រើនបំផុត គឺមកពីស្ត្រីទាំងឡាយ ដែលព្យាយាមដោយអស់សង្ឃឹម ក្នុងការធ្វើឲ្យអាពាហ៍ពិពាហ៍បានជោគជ័យ ប៉ុន្តែ នៅក្នុងការវិភាគចុងក្រោយ មិនអាចយកឈ្នះលើបញ្ហាទាំងនោះបាន ។

ចូរជ្រើសរើសដៃគូដោយប្រុងប្រយ័ត្ន និងដោយការអធិស្ឋាន ហើយនៅពេលអ្នករៀបការ ចូរមានភក្តីភាពបំផុតចំពោះគ្នា ។ ដំបូន្មានដែលមិនអាចកាត់ថ្លៃបាន គឺមកពីបន្ទះស៊ុមដ៏តូចមួយ ដែលខ្ញុំបានឃើញម្ដងនៅផ្ទះពូមីង ។ វាសរសេរថា ៖ « ជ្រើសមនុស្សដែលអ្នកស្រឡាញ់ ស្រឡាញ់មនុស្សដែលអ្នកជ្រើសរើស » ។ មាននូវគតិបណ្ឌិតដ៏អស្ចារ្យនៅក្នុងពាក្យប៉ុន្មានម៉ាត់នោះ ។ ការតាំងចិត្តចំពោះអាពាហ៍ពិពាហ៍គឺជាការចាំបាច់ទាំងស្រុងតែម្ដង ។

ភរិយារបស់អ្នកគឺស្មើគ្នានឹងអ្នក ។ ក្នុងអាពាហ៍ពិពាហ៍ ដៃគូមិនខ្ពស់ជាង ហើយក៏មិនទាបជាងគ្នាដែរ ។ អ្នកដើរទន្ទឹមគ្នាជាបុត្រាបុត្រីនៃព្រះ ។ មិនត្រូវបន្ទាបបន្ថោក ឬប្រមាថនាងឡើយ តែត្រូវគោរព និងស្រឡាញ់នាងវិញ ។ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍ថា « បុរសណាក៏ដោយដែលនៅក្នុងសាសនាចក្រនេះ ...ដែលអនុវត្តការត្រួតត្រាដែលមិនសុចរិតទៅលើ [ ប្រពន្ធរបស់ខ្លួន ] នោះគ្មានភាពស័ក្តិសមនឹងកាន់បព្វជិតភាពទេ ។ ទោះជាគាត់ត្រូវបានតែងតាំងរួចក៏ដោយ ក៏ស្ថានសួគ៌នឹងថយចេញ ព្រះវិញ្ញាណនឹងសោកសង្រេង ហើយសិទ្ធិអំណាចនៃបព្វជិតភាពរបស់បុរសនោះត្រូវចប់ហើយ » ។ ប្រធាន ហាវើដ ដបុលយូ ហ៊ីនធើរ បានមានប្រសាសន៍ពីអាពាហ៍ពិពាហ៍ថា ៖ « អាពាហ៍ពិពាហ៍ដ៏រីករាយ និងជោគជ័យ ជាទូទៅ មិនជាបញ្ហាខ្លាំងជាមួយនឹងការរៀបការមនុស្សត្រឹមត្រូវម្នាក់ ដូចជាការ *ក្លាយជា* មនុស្សត្រឹមត្រូវម្នាក់នោះទេ... ។ ការប្រឹងប្រែងដ៏មានមនសិការ ដើម្បីធ្វើនូវផ្នែករបស់ខ្លួនឲ្យពេញទំហឹងនោះ គឺជាកត្តាដ៏អស្ចារ្យបំផុតដែលធ្វើឲ្យមានជោគជ័យ » ។

ជាច្រើនឆ្នាំកន្លងមកហើយ នៅក្នុងវួដដែលខ្ញុំជាអធិបតី ក្នុងនាមជាប៊ីស្សព នៅទីនោះមានប្ដីប្រពន្ធមួយគូ ដែលមានការទាស់ទែងខ្លាំងៗជាញឹកញាប់ ។ ម្នាក់ៗប្រាកដថាខ្លួនត្រូវ ។ ក៏មិនបានស្រែកទៅនរណាម្នាក់ដែរ ។ ពេលដែលពួកគេមិនឈ្លោះគ្នា ពួកគេមាននូវអ្វីដែលខ្ញុំហៅថាជា « ការផ្អាកសង្គ្រាមដែលមិនងាយស្រួល » ។

នៅព្រឹកមួយ ម៉ោង 2 ព្រឹក ខ្ញុំបានទទួលទូរស័ព្ទពីប្តីប្រពន្ធនោះ ។ ពួកគេចង់និយាយជាមួយខ្ញុំ ហើយពួកគេចង់និយាយពេលនោះតែម្តង ។ ខ្ញុំចុះពីលើគ្រែ ស្លៀកពាក់ ហើយបានទៅផ្ទះពួកគេ ។ ពួកគេអង្គុយនៅជ្រុងផ្សេងគ្នានៅក្នុងបន្ទប់ ដោយមិននិយាយរកគ្នាទេ ។ ប្រពន្ធនិយាយទៅកាន់ប្តីតាមរយៈខ្ញុំ ។ ប្តីបានឆ្លើយតបទៅប្រពន្ធដោយនិយាយមកកាន់ខ្ញុំដែរ ។ ខ្ញុំបានគិតថា « តើយើងធ្វើឲ្យប្តីប្រពន្ធនេះនៅជាមួយគ្នាដោយរបៀបណាបានទៅ ? »

ខ្ញុំបានអធិស្ឋានសម្រាប់ការបំផុសគំនិត ហើយខ្ញុំមានគំនិតមួយថានឹងសួរពួកគេសំណួរមួយ ។ ខ្ញុំបានសួរថា « តើយូរប៉ុណ្ណាហើយ តាំងពីអ្នកបានទៅព្រះវិហារបរិសុទ្ធ ហើយធ្វើជាសាក្សីចំពោះការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ? » ពួកគេបានទទួលស្គាល់ថា វាយូរណាស់មកហើយ ។ ទោះជាយ៉ាងណា ពួកគេជាមនុស្សមានភាពស័ក្តិសម ដែលកាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធ ហើយបានទៅព្រះវិហារបរិសុទ្ធ ហើយបានធ្វើពិធីការបរិសុទ្ធសម្រាប់អ្នកផ្សេង ។

ខ្ញុំបាននិយាយទៅពួកគេថា « តើអ្នកនឹងទៅព្រះវិហារបរិសុទ្ធជាមួយខ្ញុំនៅព្រឹកថ្ងៃពុធ នៅម៉ោង 8 ទេ ? យើងនឹងធ្វើសាក្សីចំពោះពិធីផ្សារភ្ជាប់មួយនៅទីនោះ » ។ ពួកគេបានសួរព្រមគ្នាថា « ពិធីរបស់នរណា ? » ខ្ញុំបានឆ្លើយថា « ខ្ញុំមិនដឹងទេ ។ វានឹងជារបស់នរណាម្នាក់ដែលនឹងរៀបការនៅព្រឹកនោះឯង » ។

នៅថ្ងៃពុធនោះ នៅម៉ោងដែលបានណាត់ជួប ពួកយើងបានជួបគ្នានៅព្រះវិហារបរិសុទ្ធសលត៍ លេក ។ យើងទាំងបីនាក់ បានចូលទៅក្នុងបន្ទប់ផ្សារភ្ជាប់មួយ ដោយមិនបានរំពឹងថាអ្នកនៅក្នុងបន្ទប់នោះជា អែលឌើរ អេលរ៉េ អិល គ្រីស្ទានសិន ដែលពេលនោះជាជំនួយការម្នាក់របស់កូរ៉ុមនៃពួកដប់ពីរនាក់ ជាអ្នកមានតំណែងជាអ្នកមានសិទ្ធិអំណាចទូទៅម្នាក់ បានមានវត្តមាននៅពេលនោះ ។ អែលឌើរ គ្រីស្ទានសិន ត្រូវបានណាត់ឲ្យធ្វើពិធីផ្សារភ្ជាប់សម្រាប់កូនក្រមុំកូនកំលោះក្នុងបន្ទប់នោះនៅព្រឹកនោះ ។ ខ្ញុំជឿជាក់ថា កូនក្រមុំ និងក្រុមគ្រួសាររបស់នាងបានគិតថា « ពួកគេពិតជាមិត្តភក្តិរបស់កូនកំលោះហើយ » ហើយក្រុមគ្រួសារកូនកំលោះគិតថា « ពួកគេពិតជាមិត្តភក្តិរបស់កូនក្រមុំហើយ » ។ ប្តីប្រពន្ធដែលមកជាមួយខ្ញុំបានអង្គុយដាច់ពីគ្នា ប្រហែលជាជាង 30 សង់ទីម៉ែត្រ លើកៅអីតូចមួយដែលនៅស្របនឹងជញ្ជាំង ។

អែលឌើរ គ្រីស្ទានសិន បានចាប់ផ្តើម ដោយការផ្តល់ដំបូន្មានដល់ប្តីប្រពន្ធ ដែលកំពុងរៀបការនោះ ហើយគាត់បានធ្វើដូច្នោះក្នុងរបៀបដ៏ល្អមួយ ។ គាត់បានលើកឡើងពីរបៀបដែលប្តីគួរស្រឡាញ់ប្រពន្ធគាត់ ពីរបៀបដែលគាត់គួរប្រព្រឹត្តិចំពោះនាង ដោយការគោរព និងរាបសា គោរពនាងដូចជាបេះដូងនៃផ្ទះ ។ បន្ទាប់មក គាត់បាននិយាយទៅកាន់កូនក្រមុំ ពីរបៀបដែលនាងគួរគោរពដល់ស្វាមីនាងដូចជាក្បាលនៃផ្ទះ ហើយធ្វើជាអ្នកគាំទ្រគាត់ ក្នុងគ្រប់ការណ៍ទាំងអស់ ។

ខ្ញុំបានកត់សម្គាល់ថា កាលដែល អែលឌើរ គ្រីស្ទានសិន បាននិយាយទៅកាន់កូនក្រមុំ និងកូនកំលោះ នោះប្តីប្រពន្ធដែលមកជាមួយខ្ញុំ បានរំកិលខិតកាន់តែជិតគ្នា ។ មិនយូរប៉ុន្មានពួកគេបានអង្គុយជិតគ្នាតែម្តង ។ អ្វីដែលធ្វើឲ្យខ្ញុំសប្បាយចិត្តនោះ គឺពួកគេបានរំកិលក្នុងកម្រិតប្រហែលគ្នា ។ រហូតដល់ពិធីចប់ ប្តីប្រពន្ធដែលមកជាមួយខ្ញុំ បានអង្គុយជិតគ្នាដូចជា *ពួកគេ* ជាអ្នកទើបរៀបការថ្មីថ្មោងអញ្ចឹង ។ ម្នាក់ៗបានញញឹម ។

ពួកយើងបានចាកចេញពីព្រះវិហារបរិសុទ្ធនៅថ្ងៃនោះ ហើយគ្មាននរណាម្នាក់ដឹងថា យើងជានរណា ឬហេតុអ្វីយើងបានមកនោះទេ ប៉ុន្តែមិត្តរបស់ខ្ញុំបានកាន់ដៃគ្នា ពេលពួកគេដើរចេញមកតាមទ្វារខាងមុខ ។ គេបានទុកភាពខុសគ្នារបស់គេមួយអន្លើ ។ ខ្ញុំមិនចាំបាច់និយាយអ្វីមួយម៉ាត់សោះឡើយ ។ អ្នកឃើញទេ ពួកគេបានចងចាំ ថ្ងៃរៀបការរបស់ពួកគេ និងសេចក្តីសញ្ញាដែលពួកគេបានធ្វើក្នុងដំណាក់នៃព្រះ ។ ហើយពួកគេបានតាំងចិត្តចំពោះការចាប់ផ្តើមម្តងទៀត ហើយព្យាយាមកាន់តែខ្លាំងឡើងចាប់ពីពេលនេះទៅ ។

បើអ្នករាល់គ្នាណាមួយ កំពុងមានការលំបាកក្នុងអាពាហ៍ពិពាហ៍របស់អ្នក ខ្ញុំសូមឲ្យអ្នកធ្វើអ្វីទាំងអស់ដែលអ្នកអាច ដើម្បីកែកុន ដែលជាការចាំបាច់ណាស់ ដើម្បីឲ្យអ្នកអាចរីករាយដូចកាលអ្នកទើបចាប់ផ្តើមជីវិតអាពាហ៍ពិពាហ៍របស់អ្នក ។ ពួកយើងដែលជាអ្នករៀបការក្នុងដំណាក់នៃព្រះ រៀបការសម្រាប់ពេលនេះ និងអស់កល្បជានិច្ច បន្ទាប់មកយើងត្រូវតែខិតខំឲ្យអស់ពីសមត្ថភាពដើម្បីធ្វើឲ្យវាបានជោគជ័យ ។ ខ្ញុំដឹងថា មានស្ថានភាពខ្លះ ដែលអាពាហ៍ពិពាហ៍មិនអាចសង្គ្រោះបាន ប៉ុន្តែខ្ញុំមានអារម្មណ៍យ៉ាងខ្លាំងថា ភាគច្រើនបំផុត គឺអាចបាន ហើយគួរតែបាន ។ កុំទុកឲ្យអាពាហ៍ពិពាហ៍របស់អ្នកធ្លាក់ដល់ចំណុចមួយដែលស្ថិតនៅក្នុងគ្រោះអាសន្ន ។

វាអាស្រ័យលើយើងរាល់គ្នាដែលកាន់បព្វជិតភាពនៃព្រះ ដើម្បីដាក់វិន័យចំពោះខ្លួនឯង ដើម្បីយើងអាចឈរឲ្យខ្ពស់ជាងលោកិយ ។ ទោះជាយ៉ាងណា វាសំខាន់ណាស់ ដែលយើងត្រូវគោរព និងប្រព្រឹត្តិសមរម្យចំពោះមនុស្សផ្សេងទៀត ។ ទង្វើរបស់យើងត្រូវតែកុំឲ្យគេរិះគន់បាន ។

ពាក្យសម្ដីដែលយើងនិយាយ របៀបដែលយើងប្រព្រឹត្តិចំពោះអ្នកដទៃ និងរបៀបដែលយើងរស់នៅ ទាំងអស់នោះជះឥទ្ធិពលចំពោះភាពសក្ដិសិទ្ធិរបស់យើងដែលជាបុរស និងក្មេងប្រុស ដែលកាន់បព្វជិតភាព ។

អំណោយនៃបព្វជិតភាពគឺមិនអាចកាត់ថ្លៃបានទេ ។ វាមាននូវសិទ្ធិអំណាចដើម្បីធ្វើអ្វីៗដូចជាអ្នកបម្រើរបស់ព្រះ ដើម្បីព្យាបាលអ្នកឈឺ ដើម្បីប្រសិទ្ធពរដល់ក្រុមគ្រួសារយើង និងដល់អ្នកដទៃទៀតផងដែរ ។ សិទ្ធអំណាចរបស់វាអាចទៅហួសពីរាំងននៃក្ដីស្លាប់ បន្តដល់ភាពអស់កល្បជានិច្ច ។ ពុំមានអ្វីផ្សេងទៀតនៅក្នុងលោកនេះ ដែលអាចប្រៀបធៀបជាមួយវាបានទេ ។ ការពារវា តម្កើងវា ស្រឡាញ់វា រស់នៅឲ្យមានភាពស័ក្តិសមសម្រាប់វា ។

បងប្អូនប្រុសជាទីស្រឡាញ់របស់ខ្ញុំអើយ សូមឲ្យភាពសុចរិតដឹកនាំគ្រប់ជំហានរបស់អ្នក កាលដែលយើងធ្វើដំណើរក្នុងជីវិតរបស់យើង ។ ថ្ងៃនេះ និងជានិច្ចតទៅ សូមឲ្យយើងធ្វើជាអ្នកទទួលដ៏ស័ក្តិសមនូវអំណាចដ៏ទេវភាពនៃបព្វជិតភាពដែលយើងកាន់ ។ សូមឲ្យអំណាចនោះអាចប្រទានពរដល់ជីវិតយើង និងសូមឲ្យយើងប្រើវា ដើម្បីផ្ដល់ពរជ័យដល់ជីវិតនៃអ្នកដទៃទៀតជាច្រើន ដូចជាទ្រង់ ដែលបានរស់នៅ និងសុគត សម្រាប់យើង---គឺព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះយើង ។ នេះជាការអធិស្ឋានរបស់ខ្ញុំ ក្នុងព្រះនាមដ៏ពិសិដ្ឋ និងបរិសុទ្ធរបស់ទ្រង់ អាម៉ែន ។

កំណត់ចំណាំ

1. គ និង ស 121:36, 37 ។
2. និក្ខមនំ 20:7 ។
3. អេសាយ 1:18 ។
4. គ និង ស 58:42 ។
5. សូមមើល គ និង ស 94:5 និង យ៉ូហាន 17:14 ។